-បានឃើញអនុក្រឹត្យ លេខ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងអប់រំ យុវជន និងកីឡា

-យោងតាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១ .- តែងតាំងលោក ម៉ុក ជុំន៉ ជាប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## ២- សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០០

### សេចក្ដីសំរេច លេខ ២៦ សសរ
### ស្ដីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ឆ្លងកាត់ព្រំដែនថ្នាក់ខេត្ត

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន

-បានឃើញអនុក្រឹត្យ លេខ ៧១ អនក្រ/បក ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**សម្រេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនថ្នាក់ខេត្ត-ក្រុង ចំនួន១២ ដូចខាងក្រោម ៖

| | |
|---|---|
| ១-ខេត្ត តាកែវ | ៧-ខេត្ត កំពង់ធំ |
| ២-ក្រុង កែប | ៨-ខេត្ត សៀមរាប |
| ៣-ខេត្ត កំពង់ស្ពឺ | ៩-ខេត្ត ក្រចេះ |
| ៤-ខេត្ត កំពង់ឆ្នាំង | ១០-ខេត្ត មណ្ឌលគិរី |
| ៥-ខេត្ត ពោធិ៍សាត់ | ១១-ខេត្ត ព្រៃវែង |
| ៦-ខេត្ត ឧត្តរមានជ័យ | ១២-ខេត្ត ស្វាយរៀង |

**ប្រការ ២ :** គណៈកម្មាធិការនេះមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -អភិបាលខេត្ត-ក្រុង | ប្រធាន |
| -អភិបាលរងខេត្ត-ក្រុង ០១រូប | សមាជិកអចិន្ត្រៃយ៍ |
| -ស្នងការ ឬ តំណាងនគរបាលខេត្ត-ក្រុង ០១រូប | សមាជិក |
| -ប្រធានស្នាក់ការគយ និងរដ្ឋាករ ០១រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងយោធភូមិភាគ ០១រូប (ចំពោះខេត្តដែលមានយោធភូមិភាគឈរជើង) | សមាជិក |
| -មេបញ្ជាការ ឬ តំណាងកងនាវាចរខេមរភូមិន្ទមូលដ្ឋានសមុទ្រ ( ក្រុងព្រះសីហនុ-ខេត្តកំពត ) ០១រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងតំបន់ប្រតិបត្តិការសឹករង ខេត្ត-ក្រុង ០១រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្ត-ក្រុង ០១រូប | សមាជិក |

តំណាងកម្មវិធីត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ របស់អង្គការសហប្រជាជាតិ (UNDCP) ជាអ្នកផ្តល់យោបល់ ។

អភិបាលខេត្ត-ក្រុង ជាអ្នកប្រតិបត្តិ (Focal Person) ។

សមាជិកនៃគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៣ :** គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ ៖

**១-ចំពោះខេត្ត-ក្រុង នៅជាប់ព្រំដែននៃប្រទេស ថៃ-ឡាវ-វៀតណាម:**

-សហប្រតិបត្តិការ និងសំរបសំរួលជាទ្វេភាគីនូវវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរវាងខេត្ត-ក្រុង នៃប្រទេសជិតខាងដែលមានព្រំដែនជាប់គ្នា ។

-ធ្វើអោយកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរពត៌មានតាមព្រំដែន រាល់បញ្ហាដែលពាក់ព័ន្ធនឹងការផលិតគ្រឿងញៀន ការចរាចរគ្រឿងញៀន សារធាតុផ្សំគ្រឿងញៀន និងការប្រើបំពានគ្រឿងញៀន ។

-បង្កើតនីតិវិធីរួមមួយ សំរាប់ធ្វើអោយមានទំនាក់ទំនងខាងបណ្តាញផ្លាស់ប្តូរ ប្រមូលពត៌មានពីគ្នាទៅវិញទៅមក រវាងខេត្ត-ក្រុង ដែលមានព្រំប្រទល់ជាប់គ្នានៃប្រទេសទាំងពីរ ។

-បង្កើតអោយមានទំនាក់ទំនងជិតស្និទ្ធ រវាងមន្ត្រីក្នុងវិស័យផ្សេងៗនៃការត្រួតពិនិត្យគ្រឿងញៀន និងពិភាក្សាលើផលប្រយោជន៍រួមនៅតាមព្រំដែននៃប្រទេសទាំងពីរ ។

-រៀបចំអោយមានកម្មវិធីជួបជាមួយភាគីនៃខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរអោយបានទៀងទាត់ដើម្បីពិភាក្សាអំពីបញ្ហាសន្តិសុខ សកម្មភាពប្រតិបត្តិការ និងពង្រីកកិច្ចសហប្រតិបត្តិការ ។

-ក្រៅពីភារកិច្ចខាងលើ ខេត្ត-ក្រុង ដែលជាប់ព្រំដែនក៏ត្រូវបំពេញភារកិច្ចដូចខេត្ត-ក្រុង នៅក្នុងផ្ទៃប្រទេស ដែលមានចែងក្នុងចំណុច២ ខាងក្រោមនេះដែរ ។

**២-ចំពោះខេត្ត-ក្រុង នៅក្នុងផ្ទៃប្រទេស :**

-ម្ចាស់ការលើវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្នុងភូមិសាស្ត្រ ខេត្ត-ក្រុងរបស់ខ្លួន ពិសេសគឺវិធានការបង្ការទប់ស្កាត់ កាត់បន្ថយការប្រើបំពាន និងបង្ក្រាបការផលិត ឬការដាំដុះគ្រឿងញៀន ការចរាចរគ្រឿងញៀន សារធាតុផ្សំគ្រឿងញៀន និងការប្រើប្រាស់បំពាន គ្រឿងញៀន ។

-ត្រូវមានកម្មវិធីផ្លាស់ប្តូរពត៌មាន រវាងខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយ រាល់បញ្ហាដែលពាក់ព័ន្ធការផលិតគ្រឿងញៀន ការចរាចរគ្រឿងញៀន សារធាតុផ្សំគ្រឿងញៀន និងការប្រើបំពានគ្រឿងញៀន ។

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្ត-ក្រុង ត្រូវប្រមូលផ្តុំដឹកនាំអោយបានជិតស្និទ្ធនូវមន្ត្រីដែលស្ថិតនៅក្នុងវិស័យផ្សេងៗ ពាក់ព័ន្ធនឹងការត្រួតពិនិត្យគ្រឿងញៀន សំដៅធ្វើអោយកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន នៅក្នុងខេត្ត-ក្រុង ។

**៣-គណៈកម្មាធិការប្រយុទ្ធប្រឆាំងគ្រឿងញៀនខេត្ត-ក្រុងកាត់ព្រំដែនថ្នាក់ខេត្ត-ក្រុង :**

-រាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ និងរាយការណ៍វិសាមញ្ញ មកអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ ។

**ប្រការ ៤ :** ទីតាំងរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងគ្រឿងញៀនខេត្ត-ក្រុង អាស្រ័យដោយប្រធានគណៈកម្មាធិការនេះសំរេច ។

**ប្រការ ៥ :** គណៈកម្មាធិការនេះមានលេខាធិការដ្ឋានមួយ ជាសេនាធិការក្នុងភារកិច្ចដឹកនាំ គ្រប់គ្រង លើកផែនការតាមដាន វាយតំលៃការអនុវត្តន៍ការងារ ប្រយុទ្ធប្រឆាំងគ្រឿងញៀននៅក្នុងខេត្ត-ក្រុង ។

សមាជិកអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអ្នកទទួលខុសត្រូវលើការងាររបស់លេខាធិការដ្ឋាននេះ ។ ភារកិច្ចរបស់លេខាធិការដ្ឋាននេះ អាស្រ័យដោយគណៈកម្មាធិការ ជាអ្នកកំណត់ ។

**ប្រការ ៦ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មេបញ្ជាការយោធភូមិភាគ មេបញ្ជាការកងនាវាចរខេមរភូមិន្ទ មូលដ្ឋាន សមុទ្រ ទីចាត់ការគយ និងរដ្ឋាករ អភិបាលខេត្ត-ក្រុង ស្នងការនគរបាលខេត្ត-ក្រុង មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង មេបញ្ជាការកងរាជអាវុធហត្ថ ខេត្ត-ក្រុង និងគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## ៣- ផែនការណែនាំ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០

**ផែនការណែនាំ លេខ ០៥ ផករ**

**ស្តីពីការចាត់តាំងរៀបចំព្រះរាជពិធីចំរើនព្រះជន្ម**

**សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ គ្រប់គំរប់ព្រះជន្ម**

**៦៤ យាងចូល ៦៥ ព្រះវស្សា**

***

ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ក្នុងគំរប់ព្រះជន្ម ៦៤ យាងចូល ៦៥ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី ១៨ ខែ មិថុនា ឆ្នាំ ២០០០ ខាងមុខនេះ ។

ដើម្បីសំដែងនូវកតញ្ញូតាធម៌ តបស្នងសងព្រះមហាករុណាទិគុណដ៏ខ្ពង់ខ្ពស់ ក្នុងមនោសញ្ចេតនាគោរពស្រឡាញ់ដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្តេចម៉ែ ដែលបានលះបង់ព្រះកាយពលយ៉ាងឧត្តុង្គឧត្តម រួមចំណែកយ៉ាងច្រើនជួយដល់ការងារសង្គម ក្នុងបុព្វហេតុជាតិមាតុភូមិ និង ដើម្បីចូលរួមអបអរសាទរថ្វាយព្រះពរសព្ទសាធុការបវរមហាប្រសើរ ថ្វាយចំពោះសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈ ក្នុងឱកាសព្រះរាជពិធីបុណ្យចំរើនព្រះជន្មរបស់ព្រះអង្គគំរប់៦៤ យាងចូល៦៥ព្រះវស្សានេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ ។

១-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ សាលាខេត្ត-ក្រុង សាលារៀន រោងចក្រ សហគ្រាស និងគ្រឹះស្ថានក្រុមហ៊ុនឯកជន ត្រូវរៀបចំតុបតែងលំអ ទង់ជាតិ ទង់ក្លែប បដា ពាក្យស្លោក តាំងព្រះឆាយាលក្ខណ៍សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** មានតាំងភ្លើងពណ៌ និងមានពាក្យស្លោកថ្វាយព្រះពរ ។